# គណៈកម្មការទន្លេមេគង្គ
# សេចក្តីជូនដំណឹង

## ឡាវជូនដំណឹងស្តីពីគំរោងវារីអគ្គិសនី ដន សាហុង

វៀងច័ន្ទ ប្រទេសឡាវ ថ្ងៃទី៣ តុលា ឆ្នាំ២០១៣

រដ្ឋាភិបាលឡាវបានជូនដំណឹងដល់គណៈកម្មាការទន្លេមេគង្គ ទាក់ទិនទៅនឹងសេចក្តីសម្រេចចិត្តរបស់ខ្លួនក្នុងការបន្តនូវគំរោងអភិវឌ្ឍវារីអគ្គិសនី ដនសាហុង (Don Sahong) ស្ថិតក្នុងតំបន់ ស៊ីផាន់ដន ប៉ែកខាងត្បូងនៃប្រទេសឡាវ។ ទំនប់វារីអគ្គិសនីដែលសង់លើដងទន្លេមួយនេះ នឹងដំណើរការពេញមួយឆ្នាំ និង ផលិតថាមពលអគ្គិសនីបានចំនួន២៦០ មេហ្គាវ៉ាត់ក្នុងមួយឆ្នាំ។

នៅក្នុងសេចក្តីជូនដំណឹងរបស់ខ្លួនដែលបានបញ្ជូនទៅលេខាធិការដ្ឋានគណៈកម្មាការទន្លេមេគង្គកាលពីថ្ងៃទី៣០កញ្ញា ឆ្នាំ២០១៣ ប្រទេសឡាវបានភ្ជាប់ជាមួយនូវឯកសារមួយចំនួនដូចជាការសិក្សាទៅលើលទ្ធភាពបច្ចេកទេសពេញលេញមួយដែលរួមបញ្ចូលការវាយតម្លៃពីផលប៉ះពាល់ផ្នែកបរិស្ថាន និងសង្គមរបស់គំរោង និងការសិក្សាទៅលើជលផលដែលឡាវនឹងចែករំលែកជាមួយប្រទេសជាសមាជិកដទៃទៀតរបស់គណៈកម្មាការទន្លេមេគង្គ ដូចជា ប្រទេសកម្ពុជា ថៃ និងវៀត ណាម។

"រដ្ឋាភិបាលឡាវបានអោយដឹងថា ការសាងសង់របស់គំរោងដន សាហុងនឹងត្រូវចាប់ផ្តើមក្នុងខែវិច្ឆិកាឆ្នាំ២០១៣ខាងមុខ ហើយបញ្ចប់ក្នុងខែកុម្ភៈ ឆ្នាំ២០១៨។ ដំណើរការពាណិជ្ជកម្មរបស់គំរោងអាចនឹងចាប់ផ្តើមពីខែឧសភាឆ្នាំ២០១៨។ ថាមពលទទួលបានពីគំរោងនឹងត្រូវលក់ផ្តាច់មុខទៅអោយក្រុមហ៊ុនថាមពលជាតិដែលមានឈ្មោះថាអគ្គិសនីឡាវ (Electricité du Laos, EDL) ដើម្បីផ្គត់ផ្គង់តម្រូវការអគ្គិសនីក្នុងស្រុកដែលកំពុងតែកើនឡើង។

លោក Hans Guttman នាយកប្រតិបត្តិរបស់លេខាធិការដ្ឋានគណៈកម្មការទន្លេមេគង្គបានអោយដឹងថា "ឡាវបានលើកគំរោងនេះឡើងតាមរូបភាពនៃការប្រើប្រាស់ទឹកក្នុងអាងតែមួយតាមផ្លូវទឹក ហ៊ូ សាហុង (Hou Sahong) តាមរយៈការជូនដំណឹង។ ដំណើការនេះនឹងផ្តល់លទ្ធភាពដល់ប្រទេសជាសមាជិកផ្សេងទៀតធ្វើការប៉ាន់ស្មានពីការប្រើប្រាស់ទឹករបស់គំរោង និងផលប៉ះពាល់ណាមួយចេញពីគំរោងនេះ ។

ដូចដែលបានចែងនៅក្នុងនីតិវិធីសំរាប់ការជូនដំណឹង ការពិគ្រោះយោបល់ជាមុន និងកិច្ចព្រមព្រៀងរបស់គណៈកម្មាធិការទន្លេមេគង្គ ដំណើរការជូនដំណឹងដែលបានលើកឡើងខាងលើគ្រាន់តែជាលក្ខខណ្ឌដែលត្រូវបំពេញជាមុនមួយក្នុងចំណោមលក្ខខណ្ឌ៣ផ្សេងគ្នាទាក់ទិននឹងប្រភេទផ្សេងៗរបស់គំរោងនៃការប្រើប្រាស់ទឹក នៅក្នុងអាងទន្លេមេគង្គក្រោម។ ការជូនដំណឹងនឹងតម្រូវអោយមាន ចំពោះគំរោងណាដែលប្រើប្រាស់ទឹកក្នុងអាងតែមួយពេញមួយឆ្នាំ ចំពោះគំរោងនៃការបង្វែរទឹកពីអាងទន្លេមេគង្គទៅអាងទន្លេមួយផ្សេងទៀតនៅលើដៃទន្លេមេគង្គ ហើយនិងចំពោះការប្រើប្រាស់ទឹកនៅលើទន្លេមេនារដូវវស្សា។ ព័ត៌មានពីដំណើការទាំងនេះអាចនឹងផ្តល់លទ្ធភាពដល់ប្រទេសជាសមាជិកទាំងអស់ធ្វើផែនការសំរាប់គំរោងនៃការប្រើប្រាស់ទឹករបស់ខ្លួន ។

ដំណើការ២ផ្សេងទៀតរួមមាន ការពិគ្រោះយោបល់ជាមុន និងកិច្ចព្រមព្រៀង។ ការពិគ្រោះយោបល់ជាមុននេះនឹងតម្រូវអោយមានចំពោះគំរោងនៃការប្រើប្រាស់ទឹកដែលស្មើឡើងនៅលើទន្លេមេនៃទន្លេមេគង្គក្នុងរដូវប្រាំង ចំពោះការបង្វែរទឹកពីទន្លេមេ ទៅអាងទន្លេផ្សេងទៀតក្នុងអំឡុងរដូវវស្សា ការបង្វែរទឹកដែលលើសចូលទៅក្នុងអាងផ្សេងទៀតក្នុងរដូវប្រាំង។ ចំណែកឯដំណើការនៃកិច្ចព្រមព្រៀងបែបណាមួយនោះនឹងតម្រូវអោយមានចំពោះគំរោងណាដែលបង្វែរទឹកចេញពីទន្លេមេនៃទន្លេមេគង្គចូលទៅក្នុងអាងផ្សេងៗទៀតក្នុងរដូវប្រាំង។

រដ្ឋាភិបាលឡាវបានដាក់ជូននូវការពិពណ៌នារបស់គំរោងដែលផ្តល់សេចក្តីសង្ខេបនៃឯកសារសំខាន់ៗរបស់គំរោង។ ឯកសារសំខាន់ៗទាំងនេះរួមមានការវាយតម្លៃពីផលប៉ះពាល់រយៈពេលវែង ការវាយតម្លៃពីផលប៉ះពាល់ផ្នែកបរិដ្ឋាន និងសង្គម ផែនការនៃការគ្រប់គ្រងនិងតាមដានផ្នែកសង្គម ផែនការសកម្មភាពនៃការតាំងទីលំនៅថ្មី និងឯកសារបច្ចេកទេសនៃការសាងសង់។

លេខាធិការដ្ឋានគណៈកម្មការទន្លេមេគង្គបានបញ្ជូនការជូនដំណឹង ហើយនឹងផ្តល់ឯកសារទាំងនេះ ដល់សមាជិកគណៈកម្មាធិការរួមរបស់ប្រទេសសមាជិកបីផ្សេងទៀតដើម្បីពិចារណា។

លោក Guttman បានអោយដឹងថា "នីតិវិធីសំរាប់ការជូនដំណឹង ការពិគ្រោះយោបល់ជាមុន និងកិច្ចព្រមព្រៀង ទទួលស្គាល់នូវវិធីសាស្រ្តសម្របក្នុងការអនុវត្តនីតិវិធីមួយនេះ។ ទាក់ទិននឹងបញ្ហានេះ លេខាធិការដ្ឋានគណៈកម្មការទន្លេមេគង្គនឹងជួយសម្របសម្រួលកិច្ចពិភាក្សា ផ្តល់នូវទស្សនៈ ដែលផ្អែកលើវិទ្យាសាស្រ្ត និងមិនលំអៀង ហើយនឹងដាក់ជូននូវយោបល់ផ្សេងៗដែលខ្លួនមានទាក់ទិននឹងការជូនដំណឹងនេះ ទៅកាន់គណៈកម្មាធិការរួម

របស់គណៈកម្មការទន្លេមេគង្គ" ។ "ប្រទេសឡាវបានបង្ហាញនូវឆន្ទៈរបស់ខ្លួន ក្នុងការពិភាក្សាបន្ថែមទៀតអំពីគំរោងនេះជាមួយបណ្តាប្រទេសជាសមាជិកគណៈកម្មការទន្លេមេគង្គ ប្រសិនបើមានការព្រួយបារម្ភ ឬ យោបល់ផ្សេងៗ ។

រហូតមកដល់ពេលបច្ចុប្បន្ន ក្រៅពីការជូនដំណឹងរបស់គំរោងដន សាហុង មានគំរោងផ្សេងៗទៀតចំនួន៤១ នៅលើដៃទន្លមេគង្គ ត្រូវបានជូនដំណឹងមកលេខាធិការដ្ឋានគណៈកម្មការទន្លេមេគង្គ តាមរយៈនីតិវិធីសំរាប់ការជូនដំណឹង ការពិគ្រោះយោបល់ជាមុន និងកិច្ចព្រមព្រៀង។ ក្នុងនោះ ៣គំរោងពីប្រទេសកម្ពុជា ១៧គំរោងពីប្រទេសឡាវ ២ គំរោងពីប្រទេសថៃ និង ១៩គំរោងទៀតពីប្រទេសវៀត ណាម ។ គំរោងវារីអគ្គិសនីសាយ៉ាប្វូរី (Xayaburi) គឺជាគំរោងតែមួយគត់មកទល់បច្ចុប្បន្ននេះ ដែលបានស្នើសុំធ្វើឡើងនៅលើទន្លេមេនៃទន្លេមេគង្គ ហើយដែលត្រូវបានដាក់ជូនសម្រាប់ដំណើរការនៃការពិគ្រោះយោបល់ជាមុន។

គំរោងដន សាហុង មានទីតាំងនៅក្នុងស្រុកខុង Khong ខេត្តចំប៉ាសាក់ Champasak របស់ប្រទេសឡាវ និងស្ថិតនៅតាមបណ្តោយផ្លូវទឹក ហ៊ូ សាហុង (Hou Sahong) ដែលមានប្រវែង ៥ គីឡូម៉ែត្រ និងជាផ្លូវទឹកដែលបែកចេញពីន្លេមេគង្គ និងមានចំងាយប្រហែលជា ២ គីឡូម៉ែត្រខាងលើព្រំដែនប្រទេសកម្ពុជាឡាវ។ ទំនប់វារីអគ្គិសនីសំរាប់ផលិតថាមពលមួយនេះ នឹងមានកំពស់ ៣០ម៉ែត្រ និងលាតសន្ធឹងរហូតដល់ចុងផ្លូវទឹកដែលមានទទឹងប្រវែង ១០០ម៉ែត្រ។

នីតិវិធីសំរាប់ការជូនដំណឹង ការពិគ្រោះយោបល់ជាមុន និងកិច្ចព្រមព្រៀង ត្រូវបានបង្កើតឡើងក្រោមកិច្ចព្រមព្រៀងមេគង្គឆ្នាំ១៩៩៥ ។ នីតិវិធីនេះឆ្លុះបញ្ចាំងពីការប្តេជ្ញាចិត្តរបស់បណ្តាប្រទេសជាសមាជិករបស់គណៈកម្មការទន្លេមេគង្គ ក្នុងការសហការគ្នាដើម្បីការពារបរិដ្ឋាន និងតុល្យភាពអេកូឡូស៊ីនៅក្នុងអាងទន្លេ និងការពារផលប៉ះពាល់ប្រកបដោយគ្រោះថ្នាក់។ ក្នុងគោលបំណងនៃការអនុវត្តន៍នីតិវិធីនេះ ការប្រើប្រាស់ទឹក ត្រូវបានផ្តល់និយមន័យថា គឺជាការប្រើប្រាស់ទឹកណាមួយដែលអាចមានផលប៉ះពាល់សំខាន់ ទៅលើគុណភាពទឹក និងរបបលំហូរក្នុងដងទន្លេមេគង្គ ។

## កំណាត់សំគាល់សម្រាប់និពន្ធនាយកៈ

គណៈកម្មការទន្លេមេគង្គគឺជាស្ថាប័នអន្តររដ្ឋាភិបាលមានភារកិច្ចក្នុងការសហការលើការគ្រប់គ្រងអាងទន្លេមេគង្គប្រកបដោយនិរន្តរភាពដែលរួមមានសមាជិកដូចជាប្រទេសកម្ពុជា ឡាវ ថៃ និង វៀតណាម។ គណៈកម្មការនេះត្រូវបានបង្កើតឡើងក្នុងគោលបំណងជំរុញ

អោយមានសហប្រតិបត្តិការរវាងប្រទេសជាសមាជិក។ ដូច្នេះហើយគណៈកម្មការនេះមិនមានតួនាទីជាស្ថាប័នដែលមានសិទ្ធិស្វ័យតក្នុងការត្រួតពិនិត្យទេ តែជាតួនាទីផ្តល់ប្រឹក្សាពិគ្រោះយោបល់។

ដើម្បីដោះស្រាយបញ្ហាប្រឈមនេះ គណៈកម្មការពិនិត្យមើលគ្រប់វិស័យ រួមទាំងការធានានូវនិរន្តរភាពវិស័យជលផល ការកំណត់នូវឱកាសសម្រាប់វិស័យកសិកម្ម ការធានានូវសេរីភាពផ្នែកនាវាចរ ការគ្រប់គ្រងទឹកជំនន់ និងការអភិរក្សប្រព័ន្ធជីវចម្រុះ។ អ្វីដែលមានសារៈសំខាន់ជាចម្បងគឺផលប៉ះពាល់ពីទឹកជំនន់ធ្ងនធ្ងរនាពេលអនាគត គ្រោះរាំងស្ងួត រយៈពេលយូរ និងការកើនឡើងនូវកំរិតទឹកសមុទ្រដោយសារបម្រែបម្រួលអាកាសធាតុ។គណៈកម្មការទន្លេមេគង្គមានគោលបំនងសម្របសម្រួលអោយមានកិច្ចពិភាក្សារវាងរដ្ឋាភិបាលជាសមាជិក វិស័យឯកជន និងសង្គមស៊ីវិល។

លេខាធិការដ្ឋាននៃគណៈកម្មការទន្លេមេគង្គផ្តល់នូវសេវាបច្ចេកទេស ផ្តល់ប្រឹក្សា និងរដ្ឋបាលទៅដល់បណ្តាប្រទេសជាសមាជិក។ លេខាធិការដ្ឋាននេះសម្របសម្រួលកិច្ចប្រជុំថ្នាក់តំបន់នៃបណ្តាប្រទេសជាសមាជិក និងផ្តល់យោបល់ផ្នែកបច្ចេកទេសលើការធ្វើផែនការរួម កិច្ចសម្របសម្រួល និងសហប្រតិបត្តិការ។ លេខាធិការដ្ឋានធ្វើការយ៉ាងជិតស្និទ្ធជាមួយស្ថាប័នសម្របសម្រួលរបស់ប្រទេសជាសមាជិកទាំង៤ គណៈកម្មាធិការទន្លេមេគង្គជាតិ និងភ្នាក់ងារជាតិដទៃទៀត។ បច្ចុប្បន្នសាធារណរដ្ឋប្រជាមានិតចិន និងសហព័ន្ធមីយ៉ាន់ម៉ា មានទំនាក់ទំនងជាដៃគូពិភាក្សារបស់លេខាធិការដ្ឋានគណៈកម្មការទន្លេមេគង្គ ៕

សំរាប់ព័ត៌មានបន្ថែម សូមទាក់ទងៈ

Mr. Surasak Glahan មន្ត្រីទំនាក់ទំនង

Tel: +856 263 263 or +856 20 5552 8726

Email: Surasak@mrcmekong.org